ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ សុក្រ ៥ កើត ខែ កត្តិក ឆ្នាំ កុរ សំរឹទ្ធិស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៩*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មានស្តីពី

## ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយ ឯកឧត្តម Masahiro MIKAMI ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពជប៉ុនថ្មី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នៅព្រឹកថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យឯកឧត្តម Masahiro MIKAMI ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ជួបសម្តែងការគួរសម ក្នុងខណៈដែលឯកឧត្តមត្រូវបានឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពជប៉ុនថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវក្តីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមាន ឯកឧត្តម Masahiro MIKAMI ដែលទើបទទួលបានភារកិច្ចបំពេញបេសកកម្មការទូតនៅកម្ពុជា ។

ឯកឧត្តម Masahiro MIKAMI ឯកអគ្គរដ្ឋទូតជប៉ុន ក៏បានសម្តែងនូវសេចក្តីសោមនស្សរីករាយដែលបានមកបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា និងសូមសម្តែងនូវការកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើន ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ និងការរីកចម្រើន ស្ទើរគ្រប់វិស័យ ជាពិសេស ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៧,៥% ដែលជាកំណើនមួយខ្ពស់បំផុតក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ ដែលធ្វើឱ្យប្រទេសកម្ពុជា ប្រែក្លាយជាប្រទេសដែលធ្លាប់មានចំណូលទាប (Low-Income Country) មកជាប្រទេសមានចំណូលមធ្យមកម្រិតទាប (Lower Middle-Income Country)។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** សូមអរគុណចំពោះការវាយតម្លៃខ្ពស់របស់ឯកឧត្តមឯកអគ្គរដ្ឋទូតជប៉ុន ដោយបានគូសបញ្ជាក់ថា ការសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើននេះ ដោយកម្ពុជាមានសុខសន្តិភាព ជាមួយនឹងស្ថិរភាពនយោបាយ និងស្ថិរភាពនៃម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តដ៏ត្រឹមត្រូវនូវគោលនយោបាយ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ជាមួយគ្នានេះ, ឯកឧត្តម Masahiro MIKAMI បានបញ្ជាក់ជូនថា ក្នុងអាណិត្តបំពេញភារកិច្ចការទូតនេះ ឯកឧត្តមនឹងបន្តខិតខំពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងបន្តការគាំទ្រនូវការផ្តល់ហិរញ្ញប្បទាន សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ (ODA) ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង, ឥណទានសម្បទាន និងជំនួយបច្ចេកទេស ជាពិសេស ជំរុញការអភិវឌ្ឍវិស័យឯកជននានា ឱ្យកាន់តែរីកចំរើនបន្ថែមទៀត និងសូមថ្លែងអំណរគុណចំពោះឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ក៏ដូចជា ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នពាក់ព័ន្ធ ដែលតែងតែបានផ្តល់នូវកិច្ច-សហប្រតិបត្តិការដ៏ល្អប្រសើរ រវាងប្រទេសកម្ពុជា-ជប៉ុន នាពេលកន្លងមក ។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលជប៉ុន ដែលបានផ្តល់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជាតាំងដើមរៀងមក ដែលសកម្មភាពទាំងនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ប្រទេសជប៉ុន ជាដៃគូយុទ្ធសាស្ត្រអភិវឌ្ឍន៍ដ៏សំខាន់ ក្នុងការចូលរួមចំណែកជួយគាំទ្រដល់ប្រទេសកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានសម្តែងនូវការកោតសសើរ និងថ្លែងអំណរគុណផងដែរ ចំពោះលំហូរទុន និងទំហំនៃការវិនិយោគឯកជនពីប្រទេសជប៉ុន ដែលមានចំនួនកើតឡើងជាបន្តបន្ទាប់ ដែលបានជួយជំរុញអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ។ ជាមួយគ្នានេះ, ដើម្បីលើកកម្ពស់ការវិនិយោគពីវិស័យឯកជន ទាក់ទាញអ្នកវិនិយោគិន, ភាពប្រកួតប្រជែងដើម្បីជំរុញពិពិកម្មសេដ្ឋកិច្ច, រាជរដ្ឋាភិបាលកម្ពុជា ខិតខំបន្តពង្រឹងច្បាប់, កំណែទម្រង់អភិបាលកិច្ច, រួមមាន÷ ការកែលម្អប្រព័ន្ធឡូជីស្ទិក និងការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន, ប្រព័ន្ធគ្រប់គ្រង និងមធ្យោបាយដឹកជញ្ជូន សម្រួលដល់បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច និងការវិនិយោគ ឱ្យស្របទៅនឹងការរីកចម្រើននូវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានាពេលបច្ចុប្បន្ន ។ ក្នុងន័យនេះ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស្នើឯកឧត្តមឯកអគ្គរដ្ឋទូតជប៉ុន បន្តជួយសម្របសម្រួលដើម្បីទាក់ទាញអ្នកវិនិយោគជប៉ុនឱ្យបានច្រើនបន្ថែមទៀត ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏សូមជូនពរឯកឧត្តម Masahiro MIKAMI ឱ្យទទួលបាននូវជោគជ័យ សម្រាប់ការបំពេញភារកិច្ច ជាឯកអគ្គរដ្ឋទូតជប៉ុនថ្មី នៅកម្ពុជា ។

***************